**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង**
**អំពើជួញដូរមនុស្ស**
**អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ**
ក្រុមជំនួយកិច្ចការសហប្រតិបត្តិការជាតិ និងអន្តរជាតិ
លេខ.......................................

# របាយការណ៍

## បូកសរុបលទ្ធផលការងារប្រចាំខែឧសភា ឆ្នាំ២០២២

**ក-អំពីកម្លាំង៖**

សរុបបួមចំនួន៖ ០៥នាក់ (ស្រី០២នាក់) អវត្តមាន៖ ០០

**ខ-សកម្មភាព និងលទ្ធផលការងារ**

ខ.១-កិច្ចប្រជុំពង្រឹងកិច្ចសហប្រតិបត្តិការ ការកសាងគោលនយោបាយ និងបទដ្ឋានគតិយុត្តិនានា

*សកម្មភាពក្នុងស្រុក*

- **ថ្ងៃទី៥-៦ ខែឧសភា ឆ្នាំ២០២២** លោកជំទាវ ឧត្តមសេនីយ៍ទោ រ៉ន សិរិលក្ខិណា បានអញ្ជើញអមដំណើរ **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានក្រុមប្រឹក្សាជាតិដើម្បីកុមារ ចូលរួមក្នុងកិច្ចប្រជុំការពាររបាយកាណ៍ថ្នាក់ជាតិលើកទី៤ ទី៥ និងទី៦ ស្តីពីការអនុវត្តអនុសញ្ញាសិទ្ធិកុមារ ក្នុងកិច្ចប្រជុំលើកទី៩០ របស់គណៈកម្មាធិការសិទ្ធិកុមារ (CRC) អង្គការសហប្រជាជាតិ នៅទីក្រុងហ្សឺណែវ ប្រទេសស្វីស។ **លោកជំទាវ ជូ ប៊ុនអេង** បានដឹកនាំគណៈប្រតិភូកម្ពុជាមានចំនួន៦រូប ដែលមានលោកជំទាវ ញ៉េប សុភាព អគ្គនាយកក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ លោកជំទាវ សម្បត្តិ សុគន្ធា អគ្គនាយករងនៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ឯកឧត្តមបណ្ឌិត ឌី ខាំបូលី អគ្គនាយករងនៃក្រសួងអប់រំយុវជន និងកីឡា លោកជំទាវ រ៉ន សិរីលក្ខិណា អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋានគ.ជ.ប.ជ លោក ណុប ឬទ្ធា ប្រធានផ្នែកការពារកុមារ និងត្រួតពិនិត្យនៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ និងមានការចូលរួមពី ឯកឧត្តម អន សុឃឿន ឯកអគ្គរដ្ឋទូត និងជាតំណាងអចិន្ត្រៃយ៍ និងសហការី តំណាងពីនាយកដ្ឋានសុខាភិបាល សង្គមកិច្ច និងកិច្ចការនារី នៃទីស្តីការគណៈរដ្ឋមន្ត្រី ប្រធានផ្នែកការពារកុមារនិងពិនិត្យតាមដាន នៃអគ្គលេខាធិការដ្ឋាន ក.ជ.ក និងសមាជិកគណៈប្រតិភូ បានទទួលឆ្លើយសំណួរចំនួន១០០ ដែលបានចោទសួរពីសំណាក់សមាជិកគណៈកម្មាធិការ ក្នុងរយៈពេលសរុបត្រឹម៤ម៉ោង និងមានវេលា៤៨ម៉ោងរាយការណ៍បន្ថែមជាលាយលក្ខណ៍អក្សរ ជុំវិញការអនុវត្តអនុសញ្ញាសិទ្ធិកុមារនៅកម្ពុជា ។ គួររំលឹកផងដែរថាគណៈកម្មាធិការសិទ្ធិកុមារ (CRC) គឺជាស្ថាប័ននៃអ្នកជំនាញឯករាជ្យចំនួន ១៨ ដែលត្រួតពិនិត្យការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមារដោយរដ្ឋភាគីរបស់ខ្លួន (CRC)ក៏តាមដានការអនុវត្តពិធីសារជាជម្រើសពីរចំពោះអនុសញ្ញាស្តីពីការចូលរួមរបស់កុមារក្នុងជម្លោះប្រដាប់អាវុធ និងការលក់កុមារ ពេស្យាកម្មកុមារ និងរូបភាពអាសអាភាសកុមារ។ ក្នុងរយៈពេល ៣០ ឆ្នាំកន្លងមកនេះ ជីវិតរបស់កុមារត្រូវបានផ្លាស់ប្តូរដោយសន្ធិសញ្ញាសិទ្ធិមនុស្សដែលត្រូវបានផ្តល់ សច្ចាប័នយ៉ាងទូលំទូលាយបំផុតក្នុងប្រវត្តិសស្ត្រ។

អនុសញ្ញាស្តីពីសិទ្ធិកុមារបានបំផុសគំនិតរដ្ឋាភិបាលឱ្យផ្លាស់ប្តូរច្បាប់ និងគោលនយោបាយ ដូច្នេះកុមារកាន់តែច្រើនទទួលបានការថែទាំសុខភាព និងអាហារូបត្ថម្ភដែលពួកគេត្រូវការ មានការការពារប្រសើរជាងមុន ដើម្បីការពារកុមារពីអំពើហិង្សា និងការកេងប្រវ័ញ្ច ។

- **ថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២២** លោកស្រី វរសេនីយ៍ទោ ថោង សុវត្តី អនុប្រធានក្រុមជំនួយកិច្ចការសហប្រតិបត្តិការជាតិ និងអន្តរជាតិ បានអញ្ជើញចូលរួមកិច្ចប្រជុំបច្ចេកទេស ស្តីពីការពិនិត្យរបាយការណ៍វាយតម្លៃដោយស្ម័គ្រចិត្តលើកាអនុវត្ត GCM ថ្នាក់ជាតិ ដើម្បីត្រៀមចូលរួមវេទិកាវាយតម្លៃការងារអភិបាលកិច្ចទេសន្តរប្រវេសន៍ជាតិ (IMRF) ក្រោមអធិបតីភាព **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ដោយមានការអញ្ជើញចូលរួមពី ឯកឧត្តម ញឹក វណ្ណារ៉ា រដ្ឋលេខាធិការ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ឯកឧត្តម ហ៊ូ វុឌ្ឍី រដ្ឋលេខាធិការ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឯកឧត្តម កែវ វិសិដ្ឋ អនុរដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ លោកជំទាវ ជូ ពុទ្ធានី អនុរដ្ឋលេខាធិការក្រសួងផែនការ លោកស្រី គ្រីស្ទីន ផាកូ ប្រធានបេសកកម្ម អង្គការ IOM លោកជំទាវ ឧត្តមសេនីយ៍ឯក វេជ្ជ. ប៉ុណ្ណ សំខាន់ អគ្គលេខាធិការ គ.ជ.ប.ជ ឯកឧត្តម ប៉ែន ពេជ្រសាលី អគ្គនាយក ក្រសួងយុត្តិធម៌ លោកជំទាវ នាយឧត្តមសេនីយ៍ យក់ សុខា អគ្គស្នងការរងនគរបាលជាតិ ឯកឧត្តម ឧត្តមសេនីយ៍ឯក អ៊ុក ហៃសីឡា អគ្គនាយករងអគ្គនាយកដ្ឋានអន្តោប្រវេសន៍ លោកជំទាវ ឧត្តមសេនីយ៍ឯក លឹម រស្មី អគ្គនាយក អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ឯកឧត្តម លោកជំទាវ អគ្គលេខាធិការរង គ.ជ.ប.ជ តំណាងក្រសួងសុខាភិបាល តំណាងទីចាត់ការការងារព្រំដែន តំណាងនាយកដ្ឋានព្រំដែនទឹក ព្រំដែនគោក នៃអគ្គស្នងការដ្ឋាននគរបាលជាតិ តំណាងអង្គការ ILO តំណាងអង្គការ UNICEF តំណាងអង្គការ UNW-SAF និងមន្ត្រីបច្ចេកទេសពាក់ព័ន្ធមួយចំនួនទៀតផងដែរ សរុបចំនួន ៣១ រូប (ស្រី១២រូប)។

- **ថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២២** លោកជំទាវ ឧត្តមសេនីយ៍ទោ រ៉ន សិរីលក្ខិណា អគ្គលេខាធិការរង ក្រុមជំនួយកិច្ចការសហប្រតិបត្តិការជាតិ និងអន្តរជាតិ និងជាប្រធានក្រុមការងារព័ត៌មានវិទ្យា បានដឹកនាំកិច្ចប្រជុំពិភាក្សា និងធ្វើបទបង្ហាញ សាកល្បងលើប្រព័ន្ធត្រួតពិនិត្យទិន្នន័យលំហូររបស់ពលករ សម្រាប់ប្រើប្រាស់ក្នុងអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ និងនៅតាមមណ្ឌលទទួលពលករតាមព្រំដែន។ សមាសភាពអញ្ជើញចូលរួមក្នុងកិច្ចប្រជុំ មានឯកឧត្តម លោកជំទាវ ជាអគ្គលេខាធិការរង ទទួលបន្ទុកការងារសហប្រតិបត្តិការជាតិ និងអន្តរជាតិ និងឯកឧត្តម ឧត្តមសេនីយ៍ត្រី តៃ សុថារ៉េត អគ្គលេខាធិការរង ទទួលបន្ទុកការងារអនុវត្តច្បាប់ នៃគ.ជ.ប.ជ លោក លោកស្រី ជាមន្ត្រីនៃក្រុមជំនួយកិច្ចការទាំង៦ លេខាធិការដ្ឋាន នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ជាសមាជិករបស់ក្រុមការងារព័ត៌មានវិទ្យា អ្នកបច្ចេកទេស អភិវឌ្ឍលើកម្មវិធីទិន្នន័យ លោកស្រី ជាប្រធានមណ្ឌលសំចតប៉ោយប៉ែត និងមន្ត្រីរបស់មណ្ឌលសំចត មន្ត្រី និងបុគ្គលិករបស់មណ្ឌលទទួលពលករកំរៀង។

- **ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២២** លោកស្រី វរសេនីយ៍ទោ ថោង សុវត្តី អនុប្រធានក្រុមជំនួយកិច្ចការសហប្រតិបត្តិការជាតិ និងអន្តរជាតិ បានអញ្ជើញចូលរួមជាគ្រូឧទ្ទេសក៍ក្នុងពិធីបើកវគ្គបណ្តុះបណ្តាលស្តីពី “ការអង្កេតសញ្ញាណនៃការប៉ះទង្គិចផ្លូវចិត្តទៅលើជនរងគ្រោះដោយអំពើជួញដូរមនុស្ស” ក្រោមអធិបតីភាព លោក

ជំទាវឧត្តមសេនីយ៍ឯក វេជ្ជ. ប៉ុណ្ណ សំខាន់ អគ្គលេខាធិការ គ.ជ.ប.ជ ។ វគ្គបណ្តុះបណ្តាលមានគោលបំណង សំខាន់ក្នុងការពង្រឹងការអនុវត្តវិធីសាស្ត្រគាំទ្រ និងការពារប្រកបដោយប្រសិទ្ធភាព និងធ្វើឱ្យប្រសើរឡើងនូវការ អង្កេតការប៉ះទង្គិចផ្នែកផ្លូវចិត្ត របស់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស។ ចូលរួមជាគណៈអធិបតីក្នុងពិធី បើក រួមមាន លោកជំទាវ លំ គន្ធារី អភិបាលរង នៃគណអភិបាល និងជាអនុប្រធាន គ.ខ.ប.ជ ខេត្តកំពង់ធំ លោកឧត្តមសេនីយ៍ទោ សេក ស៊ីវេត ប្រធានក្រុមជំនួយកិច្ចការការពារជនរងគ្រោះ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ លោក ឯក សំអុល មន្ត្រីថ្នាក់ជាតិនៃអង្គការ IOM ប្រចាំនៅប្រទេសកម្ពុជា និងតំណាងនាយកដ្ឋានប្រឆាំងការ ជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ។ សមាសភាពសិក្ខាកាមសរុបចំនួន ៤០ រូប មកពីខេត្តកំពង់ចាម និងខេត្តកំពង់ធំ ជាមន្ត្រីជំនាញនៃមន្ទីរសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា មន្ទីរកិច្ចការនារី ការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជននៃស្នងការដ្ឋាននគរបាលខេត្តកំពង់ធំ និងអង្គការទស្សនៈពិភពលោក( World Vison )។

- **ថ្ងៃទី១៦-១៧ ខែឧសភា ឆ្នាំ២០២២** លោកជំទាវ ឧត្តមសេនីយ៍ទោ រ៉ន សិរីលក្ខិណា អគ្គលេខាធិការរង ទទួលបន្ទុកក្រុមជំនួយកិច្ចការ សហប្រតិបត្តិការជាតិ និងអន្តរជាតិ បានសហការរៀបចំវគ្គបណ្តុះបណ្តាលស្តីពីៈ “កិច្ចការពារកុមារ និង ការកំណត់អត្តសញ្ញាណ ជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស និងការរំលោភបំពាន - Training on Child Protection and Identification of Human Trafficking and Abuse” នាសាលប្រជុំសាលា ខេត្តសៀមរាប។ វគ្គបណ្តុះបណ្តាលនេះកើតឡើង ក្រោមកិច្ចសហការរវាង អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ជាមួយក្រសួងសុខាភិបាល ដោយមានជំនួយឧបត្ថម្ភពីសហភាពអឺរ៉ុប (EU) តាមរយៈអង្គការយូនីសេហ្វ ក្នុង គោលបំណងផ្សព្វផ្សាយឱ្យបានកាន់តែទូលំទូលាយ និងពង្រឹងសមត្ថភាពជាពិសេសការអនុវត្តក្រមសីលធម៌ របស់មន្ត្រី នៅទីកន្លែងធ្វើចត្តាឡីស័ក ដែលបានអនុវត្តផ្ទាល់នៅមូលដ្ឋានសរុបចំនួន ៣៨រូប (ស្រី១៨រូប) អញ្ជើញមកពីខេត្តសៀមរាប និងបន្ទាយមានជ័យក្នុងចំណោមអ្នកចូលរួមសរុប ៤៦រូប (ស្រី២២រូប) ក្នុងការ កំណត់អត្តសញ្ញាណជនរងគ្រោះជាពិសេសស្ត្រី និងកុមារការបញ្ជូនករណីកុមាររងគ្រោះ និងងាយរងគ្រោះទៅ កាន់សេវាសមស្រប ដើម្បីធានា ការការពារ និង សុខមាលភាពរបស់កុមារ ដែលទទួលរងផលប៉ះពាល់ពីចំណាក ស្រុក។ អញ្ជើញចូលរួមជាគណៈអធិបតីក្នុងពិធីបើកវគ្គមាន លោកជំទាវ ឧត្តមសេនីយ៍ទោ រ៉ន សិរីលក្ខិណា អគ្គ លេខាធិការរង នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ លោកស្រី ចាន់ កញ្ញា មន្ត្រីសម្របសម្រួលគម្រោងតំណាង អង្គការយូនីសេហ្វ លោកស្រី យីវ សុខុម ប្រធាន គ.ក.ស.ក ខេត្តបន្ទាយមានជ័យ និងពិធីបិទវគ្គ ក្រោមអធិបតី លោកជំទាវ ឧត្តមសេនីយ៍ឯក វេជ្ជ. ប៉ុណ្ណ សំខាន់ អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ លោក ជំទាវ យូ សុភា ប្រធាន គ.ខ.ប.ជ ខេត្តសៀមរាប លោកស្រី ចាន់ កញ្ញា លោកស្រី យីវ សុខុម និងលោកស្រី ព្រំ សុខន ប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងសមាហរណកម្មជនរងគ្រោះ នៃក្រសួងសង្គមកិច្ចអតីត យុទ្ធជន និងយុវនីតិសម្បទា។ ចូលរួមជាគ្រូឧទ្ទេសរួមមានលោកជំទាវឧត្តមសេនីយទោ រ៉ន សិរីលក្ខិណា អគ្គ លេខាធិការរង ទទួលបន្ទុកក្រុមជំនួយកិច្ចការសហប្រតិបត្តិជាតិ និងអន្តរជាតិ, លោកឧត្តមសេនីយទោ កែវ ផល្លា ប្រធានក្រុម ជំនួយកិច្ចការយុត្តិធម៌, លោកវរសេនីយ៍ឯក តាវ វេកក្តិ លោកស្រី វេជ្ជបណ្ឌិត តេង ស្រី អនុ

ប្រធាននាយកដ្ឋាន ប្រយុទ្ធជំងឺឆ្លង នៃក្រសួងសុខាភិបាល, លោកស្រី ព្រំ សុខន ប្រធាននាយកដ្ឋាន ប្រឆាំងការជួញដូរមនុស្ស និង សមាហរណកម្ម ជនរងគ្រោះ និង លោកគ្រូ ស៊ាង លាប អ្នកប្រឹក្សាចិត្តសាស្ត្រ នៃអង្គការធីភីអូ និងលោកអនុសេនីយ៍ឯក ហុក ដារី មន្ត្រីនៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ជាអ្នកសម្របសម្រួលកម្មវិធី។

- **ថ្ងៃទី១៨-១៩ ខែឧសភា ឆ្នាំ២០២២** លោកជំទាវ ឧត្តមសេនីយ៍ទោ រ៉ន សិរីលក្ខិណា អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ បានបន្តរៀបចំវគ្គបណ្តុះបណ្តាលស្តីពី៖ "កិច្ចការពារកុមារ និង ការកំណត់អត្តសញ្ញាណជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស និងការរំលោភបំពាន - Training on Child Protection and Identification of Human Trafficking and Abuse" សម្រាប់ក្រុមទី២ នាសាលប្រជុំសាលា ខេត្តសៀមរាប ។ វគ្គបណ្តុះបណ្តាលនេះ មានគោលបំណងដូចគ្នានឹងវគ្គទី១ផងដែរ ដែលមានសមាសភាពសិក្ខាកាមចូលរួមសរុបចំនួន ៤៦រូប (ស្រី១៦រូប) អញ្ជើញមកពី ខេត្តប៉ៃលិន ០៦រូប (ស្រី០១រូប) បាត់ដំបង ១៥រូប (ស្រី០៣រូប) ឧត្តរមានជ័យ ០៨រូប (ស្រី០៥រូប) និងសៀមរាប ១៧រូប (ស្រី០៦រូប) ក្នុងចំណោម អ្នកចូលរួមសរុប ៥៤រូប (ស្រី២២រូប)។ អញ្ជើញចូលរួម ពិធីបើកវគ្គក្រោមអធិបតីភាព លោកជំទាវ ឧត្តមសេនីយ៍ឯក វេជ្ជ. ប៉ុណ្ណ សំខាន់ អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ និងចូលរួមជាគណៈអធិបតីមាន លោកជំទាវ មុំ ពុទ្ធីតា អភិបាលរងខេត្ត និងជាប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ និងលោកស្រី ចាន់ កញ្ញា មន្ត្រីសម្របសម្រួលគម្រោងតំណាងអង្គការយូនីសេហ្វ និងពិធីបិទវគ្គក្រោមអធិបតីភាព លោកជំទាវ ឧត្តមសេនីយ៍ទោ រ៉ន សិរីលក្ខិណា អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ និង ចូលរួមជាគណៈអធិបតីមាន លោកជំទាវ មុំ ពុទ្ធីតា និង លោកស្រី ចាន់ កញ្ញា។ ចូលរួមជាគ្រូឧទ្ទេសរួមមាន លោកជំទាវ ឧត្តមសេនីយទោ រ៉ន សិរីលក្ខិណា អគ្គលេខាធិការរង ទទួលបន្ទុកក្រុមជំនួយកិច្ចការ សហប្រតិបត្តិជាតិ និងអន្តរជាតិ, លោកឧត្តមសេនីយទោ កែវ ផល្លាប្រធានក្រុម ជំនួយកិច្ចការយុត្តិធម៌, លោកវរសេនីយ៍ឯក តាវ វេភក្តិ លោកស្រី វេជ្ជបណ្ឌិត តេង ស្រី អនុប្រធាននាយកដ្ឋាន ប្រយុទ្ធជំងឺឆ្លង នៃក្រសួងសុខាភិបាល, លោកស្រី ព្រំ សុខន ប្រធាននាយកដ្ឋាន ប្រឆាំងការជួញដូរមនុស្ស និង សមាហរណកម្ម ជនរងគ្រោះ និងលោកគ្រូ ស៊ាង លាប អ្នកប្រឹក្សាចិត្តសាស្ត្រ នៃអង្គការធីភីអូ លោកស្រី វរសេនីយ៍ទោ ថោង សុវត្ថិ អនុប្រធានក្រុមជំនួយកិច្ចការ សហប្រតិបត្តិជាតិ និងអន្តរជាតិ និង លោកអនុសេនីយ៍ឯក ហុក ដារី មន្ត្រីនៃ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ជាអ្នកសម្របសម្រួលកម្មវិធី។

- **ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២២** ក្រុមជំនួយកិច្ចការ សហប្រតិបត្តិការជាតិ និងអន្តរជាតិ ដែលដឹកនាំដោយលោកជំទាវឧត្តមសេនីយ៍ទោ រ៉ន សិរីលក្ខិណា អគ្គលេខាធិការរង ក្រោមកិច្ចសហការជាមួយអង្គការយូនីសេហ្វ បានរៀបចំកិច្ចប្រជុំបូកសរុបលទ្ធផលនៃការអនុវត្ត បន្ទាប់ពីបានចូលរួមវគ្គបណ្តុះបណ្តាលស្តីពី៖ កិច្ចការពារកុមារ និង ការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងការរំលោភបំពាន (Meeting to conclude the result of trainings and its implementation on "Child protection and victim identification and abuse") ដែលប្រព្រឹត្តទៅនៅ សាលាខេត្តសៀមរាប ក្រោមអធិបតីភាព លោកជំទាវ ឧត្តមសេនីយ៍ឯក វេជ្ជ. ប៉ុណ្ណ សំខាន់

អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន គជបជ។ កិច្ចប្រជុំនេះបានផ្តោតសំខាន់ទៅលើលទ្ធផលនៃការអនុវត្ត ចំណេះដឹងរបស់មន្ត្រី ដែលជាសិក្ខាកាមដែលធ្លាប់បានឆ្លងកាត់វគ្គបណ្តុះបណ្តាលនេះកន្លងមកទាំងតាមរយៈ ប្រព័ន្ធវីដេអូអនឡាញ និងតាមបណ្តាខេត្តគោលដៅ។ គួររំលឹកផងដែរថា វគ្គបណ្តុះបណ្តាលនេះធ្លាប់បានធ្វើ តាមរយៈអនឡាញកន្លងមកដែលបានចែកចេញជា ៤ក្រុម ដែលមានសមាសភាព ថ្នាក់រាជធានីខេត្ត ចូលរួម ចំនួន ២៥រាជធានីខេត្តមានអ្នកចូលរួមចំនួន ២២៤០រូប និងបានចុះបើកវគ្គដោយផ្ទាល់ ដល់ខេត្តគោលដៅ ចំនួន ៧ខេត្ត ជា៥វគ្គ មានអ្នកចូលរួម ២០២រូប។ ក្រៅពីនោះ ក្រុមការងារក៏បានចុះទៅវាយតម្លៃការអនុវត្តក្រម សីលធម៌ និងនិតិវិធីប្រតិបត្តិនៅតាមមណ្ឌលចត្តាឡីស័កចំនួន១៩ខេត្ត បានរកឃើញនូវបញ្ហាប្រឈមមួយចំនួន។ សម្រាប់កិច្ចប្រជុំនាពេលនេះបានផ្តោតសំខាន់ ទៅលើកិច្ចពិភាក្សាបញ្ហាប្រឈម ដំណោះស្រាយ ផែនការសំណូមពរ ជាពិសេសមន្ត្រី ដែលអនុវត្តផ្ទាល់នៅមណ្ឌល ឬទីតាំងដែលត្រូវធ្វើចត្តាឡីស័ក ការកំណត់ផែនការសកម្មភាព ដែលត្រូវអនុវត្តបន្ត និងកិច្ចពិភាក្សាអំពីបញ្ហាគ្រប់គ្រងលើលំហូរពលករ នៅតាមច្រកព្រំដែនក៏ដូចជាការងារកំណត់ អត្តសញ្ញាណជនរងគ្រោះការផ្តល់សេវា និងគ្រប់គ្រងករណី សំខាន់ទៅលើស្ត្រី និង កុមារជាជនរងគ្រោះ។ សមាសភាពអញ្ជើញចូលរួមក្នុងកិច្ចប្រជុំនេះរួមមាន លោកជំទាវ អភិបាលរង នៃគណៈអភិបាលខេត្ត និងជា ប្រធានលេខាធិការដ្ឋាន គឧបជ មន្ត្រីការិយាល័យ សុខាភិបាលស្រុកប្រតិបត្តិ នគរបាលអន្តោប្រវេសន៍ មន្ត្រី មណ្ឌលសំចត ប៉ោយប៉ែត មន្ត្រីមណ្ឌលទទួល ពលករកំរៀង ក្រុមការងារជំនួយកិច្ចការ សហប្រតិបត្តិការជាតិ និងអន្តរជាតិ នៃអគ្គលេខាធិការដ្ឋាន គជបជ និងតំណាងអង្គការយូនីសេហ្វ ។ សមាភាពមានពីខេត្តទាំង៤ រួម មាន សៀមរាប បន្ទាយមានជ័យ បាត់ដំបង និងឧត្តរមានជ័យ ដែលមានសមាសភាពចូលរួមសរុបចំនួន ៤៧រូប (ស្ត្រី១៨រូប)។

- **ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២២** លោកជំទាវ ឧត្តមសេនីយ៍ទោ រ៉ន សិរីលក្ខិណា អគ្គលេខាធិការរង លោក ឧត្តមសេនីយ៍ត្រី អ៊ិន មាន ប្រធានក្រុមជំនួយកិច្ចការ និងលោកស្រី វរសេនីយ៍ទោ ថោង សុវត្ថិ អនុប្រធានក្រុម ជំនួយកិច្ចការ សហប្រតិបត្តិការជាតិ និងអន្តរជាតិ ដឹកនាំដោយ លោកជំទាវ រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និង ជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានអនុញ្ញាតិការស្នើសុំធ្វើឧទេស្សនាមអំពីកិច្ចការ ដែលអង្គការសេរីភាពកម្ពុជា អូស្ត្រាលីកំពុងតែអនុវត្ត និងស្វែងយល់បន្ថែមអំពីលទ្ធភាពបង្កើនកិច្ចសហប្រតិបត្តិការរវាង គ.ជ.ប.ជ ជាមួយ និង អង្គការសេរីភាពកម្ពុជាអូស្ត្រាលី។ អង្គការសេរីភាពកម្ពុជាអូស្ត្រាលី ជាអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក មួយដែលធ្វើការលើការទប់ស្កាត់ និងបញ្ឈប់ការជួញដូរកុមារី តាមរយៈការគាំទ្រ ការពង្រឹងសិទ្ធិអំណាចដល់ កុមារី និងទប់ស្កាត់អំពើហិង្សា តាំងពីឆ្នាំ២០១២។ អញ្ជើញចូលរួមក្នុងជំនួបរួមមាន ឯកឧត្តម ឧត្តមសេនីយ៍ឯក យ៉ែម ច័ន្ទណារុំ អគ្គលេខាធិការរង ក្រុមជំនួយកិច្ចការសហប្រតិបត្តិការជាតិ និងអន្តរជាតិ លោកស្រីនាយក ប្រចាំប្រទេស និងលោក សឿង សម្បត្តិ បុគ្គលិកអង្គការសេរីភាពកម្ពុជាអូស្ត្រាលី។

## ៦.២-ការងារចងក្រងព័ត៌មានតាមគេហទំព័រសារព័ត៌មាននានា (មានឧបសម្ព័ន្ធភ្ជាប់)

- <u>គ្រោះថ្នាក់ ឬហានិភ័យការងារក្នុងប្រទេសគោលដៅ</u>

- ឧបទ្ទវហេតុ ០០ នាក់
- ពលករសរុប ០០ នាក់

- ប្រព្រឹត្តបទល្មើសនៅនឹងកន្លែង
  - ចាប់ខ្លួន ០០ នាក់
  - ពលករសរុប ០០ នាក់
- ពលកររួចទោសពីពន្ធនាគារ
  - ពលករសរុប ០០ នាក់
- ពលករចំណាកស្រុកខុសច្បាប់
  - បញ្ជូនត្រឡប់ **១២៨នាក់**
  - ចាប់ខ្លួន **០៧នាក់**
  - ពលករសរុប **១៣៥នាក់**

**គ-ទិសដៅបន្ត**

- បណ្តុះបណ្តាលជំនាញក្រុមការងារព័ត៌មានវិទ្យាថ្មី

ថ្ងៃ ខែ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ ២០២២

**ប្រធាន**

**ក្រុមជំនួយកិច្ចការសហប្រតិបត្តិការជាតិ និងអន្តរជាតិ**

**ចម្លងជូន៖**

-លេខាធិការដ្ឋានរដ្ឋបាលសរុប

-លោកជំទាវអគ្គលេខាធិការរងទទួលបន្ទុក

-លោកជំទាវអគ្គលេខាធិការ

"ដើម្បីជូនជ្រាប" ជាសេចក្តីរាយការណ៍

-ឯកសារ-កាលប្បវត្តិ